# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**
**សាលាខេត្តពោធិ៍សាត់**
លេខ ១៣៩ សសរ.ពស

ពោធិ៍សាត់ ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១៤

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការខេត្តពោធិ៍សាត់ ជំរុញចលនាភូមិ១ ផលិតផល១

## អភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៤ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៣/១០៥៩ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ ដោយធ្វើសមាហរណកម្មការងារជំរុញចលនាភូមិមួយផលិតផលមួយ ឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។
- យោងសេចក្តីសម្រេចលេខ០៩៥ សសរ/ពស ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ របស់សាលាខេត្តពោធិ៍សាត់ស្តីពីការបែងចែក និងប្រគល់ភារកិច្ចជូនឯកឧត្តមអភិបាល និងអភិបាលរង នៃគណៈអភិបាលខេត្តពោធិ៍សាត់ ។
- យោងលិខិតលេខ០៣២ ភ១ ផ១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទស្តីពីការណែនាំឲ្យរដ្ឋបាលសាលារាជធានី/ខេត្តរៀបចំគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ ។
- យោងតាមការចាំបាច់របស់រដ្ឋបាលខេត្ត ។

## សម្រេច

**ប្រការ ១**.ត្រូវបានបង្កើតគណៈកម្មាធិការខេត្តពោធិ៍សាត់ ជំរុញចលនាភូមិ១ ផលិតផល១ សរសេរអក្សរកាត់ថា (គ.ខ.ភ១ផ១) ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ម៉ៅ ធនិន** | អភិបាល នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២- លោកជំទាវ | **ជុក សុផានី** | អភិបាលរង នៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៣- លោក | **ឡាយ វាសិដ្ឋ** | ប្រធានមន្ទីរកសិកម្ម | សមាជិក |
| ៤- លោក | **នៃ ចាន់ណាសូជា** | ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៥- លោកស្រី | **ឃឹម សាំខាន** | ប្រធានមន្ទីរពាណិជ្ជកម្ម | សមាជិក |

សាលាខេត្តពោធិ៍សាត់ ភូមិ៣លំញែក II សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ទូរស័ព្ទ : ០១២ ៤១៣ ៩៣៧/០៥២ ៧៤៦ ៩៩៩ ទូរសារ : ០៥២ ៧៤៥ ៩៩៩
Email : pursatinfo@gmail.com

| | | | |
|---|---|---|---|
| ៦- លោក | **សំ ឃីម** | ប្រធានមន្ទីរទេសចរណ៍ | សមាជិក |
| ៧- លោកស្រី | **ម៉ែន ផល្លី** | អភិបាលរងស្តីទី នៃគណៈអភិបាលក្រុងពោធិ៍សាត់ | សមាជិក |
| ៨- លោក | **អេង រ៉ា** | នាយករងរដ្ឋបាលសាលាខេត្ត | លេខាធិការ |
| ៩- លោក | **ហ៊ិន អាន** | នាយកទីចាត់ការអន្តរវិស័យសាលាខេត្ត | ជំនួយការ |

**ប្រការ ២.** គណៈកម្មាធិការខេត្តពោធិ៍សាត់ជំរុញចលនាភូមិ១ ផលិតផល១ មានភារកិច្ចដូចខាងក្រោមនេះ ៖

- សម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយនឹងអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១ ។
- ជំរុញការអនុវត្តចលនាភូមិ១ ផលិតផល១ ឲ្យទទួលបានជោគជ័យដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល ។
- អភិវឌ្ឍធនធានមនុស្សទាក់ទងនឹងការជំរុញចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត ដើម្បីអនុវត្តចលនាភូមិ១ ផលិតផល១ ឲ្យទទួលបានជោគជ័យរួមចំណែកកាត់បន្ថយភាពក្រីក្រ កាត់បន្ថយចំណាកស្រុក លើកកម្ពស់ជីវភាពរស់នៅ និងគុណភាពជីវិតរបស់ប្រជាជនតាមសហគមន៍ ។
- ចូលរួម និងដឹកនាំការសិក្សា ស្រាវជ្រាវផលិតផល ជាសក្តានុពលនានា ដែលមានក្នុងខេត្ត ទាំងផលិតផលជាវត្ថុធាតុដើម ផលិតផលកែច្នៃ និងផលិតផលសេវាកម្មដើម្បីបញ្ចូលទៅក្នុងចលនាភូមិ១ ផលិតផល១ ដោយធ្វើយ៉ាងណាបន្តអភិវឌ្ឍផលិតផលទាំងនោះមានលក្ខណៈកាន់តែប្រសើរ កាន់តែពិសេស និងសមស្របតាមទីផ្សារទាំងក្នុងសហគមន៍ ក្នុងប្រទេស និងក្រៅប្រទេស ។
- ផ្សព្វផ្សាយឲ្យបានទូលំទូលាយពីសារៈសំខាន់នៃការជំរុញចលនាភូមិ១ ផលិតផល១ និងលើកទឹកចិត្តប្រជាជននៅតាមមូលដ្ឋានឲ្យចូលរួមគាំទ្រ និងអនុវត្តចលនានេះ ។
- សម្របសម្រួលជាមួយអង្គការ-ស្ថាប័ន និងដៃគូរអភិវឌ្ឍន៍នានានៅថ្នាក់ក្រោមជាតិ ដើម្បីជំរុញការអនុវត្តចលនាភូមិ១ ផលិតផល១ ។
- សម្របសម្រួលរៀបចំអនុវត្តយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី ផែនការសកម្មភាពជំរុញចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត ។
- រៀបចំបង្កើតសមាគមន៍គាំទ្រចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត ។
- រៀបចំបង្កើតមជ្ឈមណ្ឌលភូមិ១ ផលិតផល១ នៅក្នុងខេត្តសម្រាប់ធ្វើជាកន្លែងសិក្សាស្រាវជ្រាវ បណ្តុះបណ្តាលផ្សព្វផ្សាយ ប្រមូលផ្តុំ និងដាក់តាំងបង្ហាញ ឬលក់ផលិតផលភូមិ១ ផលិតផល១ ។
- រៀបចំបង្កើតអនុគណៈកម្មាធិការក្រុង ស្រុក ជំរុញចលនាភូមិ១ ផលិតផល១ ដោយមានសមាភាព និងតួនាទីរបស់អនុគណៈកម្មាធិការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ ។
- រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិកាដ្ឋាន នៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១ និងថ្នាក់ដឹកនាំខេត្ត និងចម្លងជូនមន្ទីរ ស្ថាប័នពាក់ព័ន្ធក្នុងខេត្ត ដើម្បីរួមសហប្រតិបត្តិការក្នុងការជំរុញចលនាភូមិ១ ផលិតផល១ ។

**ប្រការ ៣.** ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការថ្នាក់ខេត្ត ជំរុញចលនាភូមិ១ ផលិតផល១ ( គ.ខ.ភ១ផ១ ) មានដូចខាងក្រោម ៖

- គ.ខ.ភ១ ផ១ មានសិទ្ធរៀបចំបែងចែក ភារកិច្ចទទួលខុសត្រូវ លំអិតបន្ថែមទៀតសម្រាប់ជំរុញចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត និងក្រុង ស្រុក របស់ខ្លួន ។

- គ.ខ.ភ១ ផ១ មានលេខាធិការដ្ឋានមួយ ដឹកនាំដោយនាយក ឬនាយករងរដ្ឋបាលមួយរូប និងមានជំនួយការចំនួនមួយចំនួនជាមន្ត្រីរដ្ឋបាលរបស់សាលាខេត្ត ទៅតាមការចាំបាច់ ដោយមានការឯកភាពពីប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ ។
- គ.ខ.ក១ ផ១ អាចអញ្ជើញតំណាងមន្ទីរ អង្គភាពផ្សេងៗទៀតក្នុងខេត្ត តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និអន្តរជាតិ តំណាងវិស័យឯកជន និងតំណាងសហគមន៍ ឬសមាគមន៍ចចូលរួមប្រជុំផ្តល់យោបល់ ឬពិភាក្សាក្នុងការអនុវត្តការកិច្ចលើកកម្ពស់ចលនាភូមិ១ ផលិតផល១ នៅក្នុងខេត្តរបស់ខ្លួន ។
- សមាជិក គ.ខ.ភ១ ផ១ ត្រូវចូលរួមប្រជុំរៀងរាល់ ៣ខែម្តង និងករណីពិសេសណាមួយតាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការខេត្ត ជំរុញចលនាភូមិ១ ផលិតផល១។
- កិច្ចប្រជុំរៀងរាល់ ៣ខែម្តង ឬករណីពិសេសណាមួយ ត្រូវស្ថិតនៅក្រោមអធិបតីភាពប្រធានគណៈកម្មាធិការថ្នាក់ខេត្ត ជំរុញចលនាភូមិ១ ផលិតផល១ ឬអនុប្រធានគណៈកម្មាធិការដែលត្រូវបានទទួលការផ្ទេរសិទ្ធពីប្រធានគណៈកម្មាធិការ ។

**ប្រការ ៤**.រាល់សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥**.នាយករដ្ឋបាលសាលាខេត្ត លោក/លោកស្រីប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធ លោក/លោកស្រីអភិបាលក្រុងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យទទួលបានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**អភិបាល នៃគណៈអភិបាលខេត្ត**

**ម៉ៅ_ធនិន**

<u>កន្លែងទទួល</u>
- ក្រសួងមហាផ្ទៃ
- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១
- ក្រុមប្រឹក្សាខេត្តពោធិ៍សាត់
  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ
  *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ

សាលាខេត្តពោធិ៍សាត់ ភូមិពាលញែក II សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ទូរស័ព្ទ : ០១២ ៩៥៩ ១២៦ / ០៥២ ៧៤៦ ៩៩៩ ទូរសារ : ០៥២ ៧៤៥ ៩៩៩
Email : pursat.info@gmail.com